# ទំព័រជួបប្រិយមិត្ត

នាងខ្ញុំ **ម៉ៅសំណាង** សុំថ្លែងអំណរគុណដល់ប្រិយមិត្តអ្នកអានទាំងអស់ ដែលបានគាំទ្រអក្សរសាស្ត្រជាតិយើងហើយជួយគាំទ្រស្នាដៃនិពន្ធរបស់នាងខ្ញុំរហូតមក នាងខ្ញុំនឹងព្យាយាមនិពន្ធរឿងថ្មីឱ្យបានបោះពុម្ពផ្សាយជាបន្តបន្ទាប់តម្រូវតាមការអានរបស់ប្រិយមិត្តទាំងអស់

ស្នាដៃនិពន្ធរបស់នាងខ្ញុំនៅសំណេរដៃច្រើនណាស់ នាងខ្ញុំទើបតែមានលទ្ធភាពបោះពុម្ពក្នុងឆ្នាំ២០០៤នេះហើយក៏ទើបតែមានឱកាសបាន ជួបមិត្តអ្នកអានរបស់ខ្ញុំទាំងអស់ជាថ្មីម្តងទៀតតាមរយៈប្រលោមលោក ។

នាងខ្ញុំរំភើបចិត្តខ្លាំងណាស់ដែលមានមិត្តអ្នកអានជាច្រើនទូរ-ស័ព្ទមកសំណេះសំណាលសុំស្គាល់អ្នកនិពន្ធទន្សាយឱ្យបានច្បាស់ ខាងក្រោមនេះជាប្រវត្តិរូបសង្ខេបរបស់នាងខ្ញុំ :

- អ្នកស្រីម៉ៅ សំណាង កើតឆ្នាំ១៩៥៩បានសិក្សាដល់ថ្នាក់ទី១ ទំនើបជាតិក្នុងរបបសាធារណរដ្ឋលន់នល់ ។

- ឪពុកឈ្មោះម៉ៅ សោម សាស្ត្រាចារ្យខ្មែរ (ស្លាប់ក្នុងរបបប៉ុលពត)

- ម្តាយឈ្មោះ ប៉ែន ស៊ីយ៉ែន (ស្លាប់ឆ្នាំ២០០០)

- បងប្អូន៥នាក់ នាងខ្ញុំជាបងស្រីច្បង
- ស្វាមីឈ្មោះ សួន សុម៉ុនធឿន អតីតយោធាក្រុង
- មានកូន២នាក់ កូនស្រីច្បង ម៉ៅ ចាន់រស្មី កើតឆ្នាំ១៩៨៦ កូនប្រុស ម៉ៅ បញ្ញាពេជ្រ កើតឆ្នាំ១៩៨៧
- ក្លាយជាអ្នកនិពន្ធប្រលោមលោកពីឆ្នាំ១៩៨១ និពន្ធបាន ១២០ រឿង
- ក្លាយជាអ្នកនិពន្ធឆ្នាំ១៩៨៧ និពន្ធបានជាង១០០រឿង ធ្លាប់ប្រលងជាប់ចំណាត់ថ្នាក់លេខ១ពានរង្វាន់ព្រះសីហនុរាជ ជាព្រះរាជាប្រទានរបស់ព្រះបាទសម្តេចសីហនុវរ្ម័នឆ្នាំ១៩៩៥ រឿងរលកបោកខ្សាច់
- ជាប់ចំណាត់ថ្នាក់លេខ២ នៅអង្គការន័រវេស្សសង្គ្រោះកុមារ រឿងកំរង់ផ្កាម្លិះ ឆ្នាំ២០០០។
- ជាប់ចំណាត់ថ្នាក់លេខ៥ ពានរង្វាន់មហោស្រពអង្គរឆ្នាំ២០០០ រឿងឋានសួគ៌សាងបាប។
- ជាប់អត្ថបទជ្រើសរើស បកប្រែជាភាសាជប៉ុនរឿងសមុទ្រខ្មៅឆ្នាំ ២០០១
- បានទទួលគ្រឿងឥស្សរិយយសសារាភ័ណថ្នាក់សេនា ជាអ្នកនិពន្ធដែលមានស្នាដៃល្អនិងគុណបំណាច់ខ្ពស់ក្នុងការ ថែរក្សាការពារនិងបណ្តុះបណ្តាល ផ្នែកវប្បធម៌អក្សរសាស្ត្រជាតិពីសម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីទី១ឆ្នាំ ២០០៣

# វគ្គទី១

## ខ្ញុំជាអ្នកណា ?

នៅទួលគោក ភូមិគ្រិះដែលធំដាច់គេ ហើយមើលទៅមានសភាពស្ងប់ស្ងាត់ចំឡែក ធ្វើឱ្យគេតែងតែចាប់ភ្លឹកងាកមើលគ្រប់គ្នា វិឡាលោកស្នងការនៃក្រុមសំងាត់នីកាលី !

គិតទៅអ្នកធ្វើការផ្នែកនេះចូលចិត្តអ្វីដែលលាក់ការណ៍ និងអាថិកំបាំងបំផុត សូម្បីប្រវត្តិរបស់លោក នីកាលី ក៏គ្មានអ្នកណាដឹងនិងយល់ច្បាស់មែន តើប្រពន្ធរបស់គាត់នៅទីណា ? រស់ឬស្លាប់ មានកូនប៉ុន្មានដែរ ? គឺលោកមិនទាំងឱ្យស្គាល់មុខ ក្រុមគ្រួសារថែមទៀត ព្រោះលោកយល់ថា មនុស្សអាក្រក់ស្គាល់ប៉ូលីសណាស់ លោកជាមនុស្សរស់នៅក្នុងការប្រុងប្រយ័ត្នគ្រប់ជំហាន តែថ្ងៃនេះនៅក្នុងភូមិគ្រិះដ៏ស្ដឹមស្ដៃមានសភាពអ៊ូអរជាងប្រក្រតីលោកនីកាលី មាឌធំសង្រេះទុកពុកមាត់កាត់តំរឹមយ៉ាងស្អាត អាយុខ្ទង់ ៤០ ឆ្នាំហើយ តែកម្លាំងមាំមួនមុខមានអំណាចសមជាស្នងការធំនៃក្រុមសំងាត់ កំពុងជក់ខ្សៀរអង្គុយក្នុងការត្រិះរិះ នៅពីមុខលោកគឺសហការីជំនិតរបស់លោកដែលប្រចាំការជានិច្ចក្នុងវិឡា សំរាប់ការពារលោកផ្ទាល់ ភ្នាក់ងារម្នាក់សក់រួញក្រញាញ់ វាចារបៀបអានលំទោន :

- លោកម្ចាស់.....តាមយោបល់ខ្ញុំការខូចសរសៃប្រសាទ ត្រូវតែឱ្យអ្នកជម្ងឺមានឱកាសដើរចេញក្រៅត្រូវធាតុអាកាសល្អ ជូនកាលទិដ្ឋភាពជុំវិញខ្លួន ដែលមានទំនាក់ទំនងអតីតកាលរបស់គេនឹងអាចឱ្យគេនឹកឃើញបន្តិចម្តងៗ នេះជាយោបល់របស់លោកដុកទ័រ ខាងសរសៃប្រសាទ !

លោក នីកាលី ងក់ក្បាលយឺតៗ :

- អញ្ចឹងឯងនាំគេចេញមក !

បន្ទប់កញ្ចក់នេះស្អាតណាស់ ធ្វើពីក្បាច់រចនាដូចក្នុងវាំងបុរាណ តែគ្មានមនុស្សនៅទេ វ័យវុទ្ធដៃស្តាំរបស់លោកកាលី នាំគ្នីគ្នាទាំងអស់ចុចទ្វារស្វ័យប្រវត្តិកញ្ចក់ញែកចេញពីគ្នា រួចចូលទៅបង្វិលក្បាលតោដែលតាំងលើក្បាលដំណេក ស្រាប់តែគ្រែដ៏ពិចិត្រស្រុតទៅក្រោយដូចទេពនិម្មិត ពេលគ្រែអណ្តែតមកកន្លែងដើមវិញ លេចរូបបុរសម្នាក់អង្គុយច្រង៉ុក គេស្លៀកពាក់ស្អាតបាត តែភ្នែកស្រអាប់បញ្ជាក់នូវភាពវង្វេងស្មារតី សក់លប់ត្រចៀក ពុកមាត់ស្រម៉ូម រកមើលទំរង់មុខលែងបាន តែសាច់ឈាមគឺជាយុវជនក្នុងវ័យ២០ប្លាយឆ្នាំតែប៉ុណ្ណោះ បុរសនេះខូចខួរក្បាលមែន តែអ្នកដូចជាស្លូតមិនកាចដូចមនុស្សឆ្កួតខ្លះទៀតទេ ។ គេអង្គុយផ្ទឹងមើលមុខគេឯងធ្វើភ្នែកភ្លិះៗវ័យវុទ្ធ អោនគោរព :

- អ្នកប្រុសធំសុំអញ្ជើញ !



បុរសពុកមាត់ស្រម៉ូម ធ្វើងឺងើ :

- អញ្ជើញ ! អញ្ជើញទៅណា ?

- លោកម្ចាស់រង់ចាំឯបន្ទប់សាឡុង ថ្ងៃមុនក្រែងអ្នកប្រុសទារដើរលេងឬ? ឥឡូវលោកប៉ារបស់អ្នកប្រុសអនុញ្ញាតហើយ !

- អា៎ ! សប្បាយមែន ! សប្បាយណាស់ ទីនេះទើបមានខ្យល់ត្រជាក់ស្រួលម៉េចពួកឯងឱ្យខ្ញុំទៅនៅកន្លែងហាប់សឹងស្លាប់នោះទៅវិញ?

- ពួកខ្ញុំពិបាកការពារលោកប្រុសណាស់ បានជាយកទៅបន្ទប់ក្រោមដីអញ្ចឹង !

យុវបុរសខូចស្មារតី លោតចុះពីលើគ្រែក្រេះ កាយវិការគេរហ័សរហួនណាស់ បើមិនខូចខួរក្បាលពិតជាបុរសអង់អាចបំផុតវ័យវុទ្ធប្រញាប់ហូតកងមូល ពីហោប៉ៅថ្ពក់ចូលដៃ កងនោះចងភ្ជាប់ខ្សែនីឡុងឆ្មារស្វិតហើយវែងជាប់និងកងជើងរបស់បុរសស្រម៉ូមនោះ គឺគេការពារខ្លាចបុរសនេះរត់ពិបាកចាប់គេចងជើង កម្លោះឆ្កួតជាប់ខ្លាចបង្កហេតុផ្សេងៗ បុរសពីរនាក់ទៀតនាំផ្លូវ..... ។

- អ្នកប្រុសមកតាមខ្ញុំមក !

កម្លោះខូចសតិដើរតាមភ្នាក់ងារតាមសំរួល គ្រាន់តែធ្វើភ្នែកសឹៗ លោកកាលី ទាញដៃអ្នកកម្លោះឱ្យអង្គុយចុះ !

- ថ្ងៃនេះកូនស្លូតជាងថ្ងៃមុន ប៉ាត្រេកអរណាស់ រដ្ឋកាល កូននឹកឃើញខ្លះទេ ? ទីនេះជាកន្លែងអ្វី ?

រដ្ឋកាលជាឈ្មោះរបស់បុត្រលោកកាលី មាណពជ្រួញចិញ្ចើម ចូលគ្នា :

- លោកប៉ា ! ខ្ញុំគ្មានប៉ាទេ ! មានតែម៉ាក់ ! មែន ! ម៉ាក់ខ្ញុំនៅឯណា? នៅឯណា ?

កម្លោះស្រម៉ូមស្អុះងើបដូចខ្សែភ្លើងឆក់ តែត្រូវក្រុមភ្នាក់ងារចាប់ជាប់ឱ្យអង្គុយមួយកន្លែងវិញ លោកកាលី បើកភ្នែកភ្លឺភ្លែតសើចស្រស់ :

- ថ្ងៃនេះខួរក្បាលគេស្រឡះល្អជាងមុន !

មែនជិតពីរឆ្នាំនេះ យើងបង្ខាំងគេពេក ទើបមិនងាយជា ល្អណាស់លោកដុកទ័រ រ៉ូឌី ពិតជាចំណាប់មែន យើងត្រូវទុករដ្ឋកាលនៅបន្ទប់កញ្ចក់ មិនបាច់ដាក់នៅក្រោមដីទៀតទេ ហើយត្រូវខិតខំព្យាបាលគេឱ្យបានជិតដល់បំផុត !

- បាទ ! លោកម្ចាស់ !

រដ្ឋកាលត្រូវគេនាំមកសំរាកក្នុងបន្ទប់កញ្ចក់វិញ ! "រដ្ឋកាល" ពាក្យនេះមានន័យណាស់ គឺជាពេលវេលាដែលកន្លងដ៏យូរលង់ កម្លោះស្រម៉ូមអង្គុយលើកៅអីក្នុងបន្ទប់កញ្ចក់ សំឡឹងមើលទិដ្ឋភាពជុំវិញខ្លួនចិញ្ចើមគេជ្រួញជាប់ ! រដ្ឋកាល ? ជាអ្នកណា? តើខ្ញុំជាអ្នកណា ?

គិតយូរទៅខួរក្បាលគេវិលដូចផែនដី ក្រឡាប់ខ្លួនសន្លប់ស្ដូកក្រាបលើតុ លោកកាលីក្រលាស់ដៃពីក្រៅបន្ទប់កញ្ចក់សំឡឹងការប្រែ-



ប្រួលរបស់កូនប្រុសដោយដកដង្ហើមធំ! ខណៈនោះវ៉ៃយរុទ្ធចូលមកដល់:

- លោកនេះជាសំបុត្រផ្ញើមកពីតូក្យូ !

- សំបុត្ររដ្ឋនីមែនទេ ?

- បាទ ! អ្នកនាងពៅ ប្រហែលជាជិតបានវិលមកវិញហើយ !

- ល្អ យើងកំពុងរង់ចាំកូនស្រីយើងសំបើមណាស់ !

លោកកាលី លាតសំបុត្រយ៉ាងរហ័ស !

**ជូនចំពោះលោកប៉ា ដោយក្ដីនឹករលឹក !**

ប៉ាប៉ា នីឆ្ងល់ណាស់ ទឹកចិត្តនិងព្រហ្មវិហារធម៌របស់ឪពុកចំពោះកូនចុះថយឬ ? បានជាលែងឃើញផ្ញើសំបុត្រមកកូនដូច្នេះ ? ឬមួយក៏ការងាររបស់ប៉ាមមាញឹកពេក ? កូនស្រីរបស់ប៉ាទន្ទឹងរង់ចាំថ្ងៃជួបជុំដូចសំណាបរង់ចាំទឹកភ្លៀង មួយឆ្នាំគត់ដែលកូនឃ្លាតពីប៉ាឯកទេសខាងប្រើស្បែកមុខ កូនរៀនបានស្ទាត់ជំនាញណាស់ ! ប៉ាសង្ឃឹមចុះរដ្ឋនីនិងបានជួយសំរួលការងាររបស់ប៉ាខ្លះៗ ពេលក្រសួងប៉ាត្រូវការរូបកូន ឥឡូវកូនរៀនចប់ហើយ កូនត្រូវវិលមកវិញ នៅខែក្រោយ សុំប៉ារង់ចាំទទួលកូនស្រីរបស់ប៉ាផង !

រដ្ឋនីកូនស្រីប៉ា

លោកកាលីញញឹមស្រស់

- យើងមានជំនួយថែមម្នាក់ទៀតហើយ ពួកឯងយល់ហើយមែនទេ ពីកិច្ចការរបស់យើង ?

- បាទ ! យល់ !

- អាទិត្យក្រោយរៀបចំទទួលកូនស្រីយើងឱ្យបានល្អ !

វជ្ជកាលស្ងួតតែមិនងាយឱ្យអ្នកណាចូលជិតទេ ទើបពុកមាត់គេត្រូវដុះស្រម៉ូម នារីបំរើម្នាក់ចូលងូតទឹកឱ្យ តែអ្នកកម្លោះបើកភ្នែកដាក់ទាល់តែនាងខ្លាចលែងហ៊ានចូលជិត អ្នកប្រុសនៃត្រកូលរុងរឿងពុំសមអភ័ព្វបែបនេះសោះ វជ្ជកាលរើពេញគ្រែ :

- ក្តៅស្ទះណាស់ នាំយើងទៅកន្លែងស្រួលទៅ កុំទុកយើងនៅក្នុងហិប !

លោកកាលី បន្ទូរដង្ហើមធំ :

- វីយរុទ្ធ យកឡាន មកនាំគេទៅយកខ្យល់អាកាសបន្តិចមើល តែត្រូវប្រយ័ត្នឱ្យមែនទែន បើបាត់វជ្ជកាលពួកឯងជាអ្នកទទួលខុសត្រូវទាំងស្រុង :

- បាទ !

វជ្ជកាលឈានចុះពីឡាន ពេលឃើញទេសភាពមាត់ទន្លេ មានខ្យល់រំភើយសែនត្រជាក់ កម្លោះរត់កាត់វាលស្មៅគ្រវីដៃដោយរីករាយអ្នកណាក៏តាមមើលវជ្ជកាលដែរ !

គេចាត់ទុកអ្នកជាមនុស្សឆ្កួតគួរអាណិត វីយរុទ្ធរត់តាមក្រោយ



វជ្ជកាលជាប់ ខ្លាចរត់បាត់ នារីម្នាក់កំពុងឈរថតយកទេសភាពជងទន្លេងាកមុខមកចំវជ្ជកាល នាងតាមមើលគេដោយងឿងឆ្ងល់ "មនុស្សឆ្កួតបែបនេះ ជាស្ថិតនៅក្នុងត្រកូលខ្ពស់ណាស់ បានជាគេតាមបំរើឆ្វេងស្តាំ" វជ្ជកាលងាកចាំមុខនាងដែរ ស្រាប់តែគេឈរភាំង បើកភ្នែកធំៗស្ទុះមករកនាងក្រមុំតែម្តង :

- ម៉ាឡាអូន ! ម៉ាឡា......

ស្រីស្រស់ដែលមានរូបឆោមលោមពណ៌ស្អែនសោភា ស្ថិតក្នុងវ័យ២០ ឆ្នាំយ៉ាងច្រើនរត់ដោយភ័យខ្លាច ។

- ទេ ! អ្នកណាជាម៉ាឡា របស់អ្នកឯង ?

វីយរុទ្ធនិងគ្នីគ្នាក៏នាំគ្នាភាំងដែរ ស្ទុះមកចាប់អោបវជ្ជកាលជាប់ :

- អ្នកប្រុស !

មាណពឈរថ្ងឹងសំឡឹងស្រីល្អ ដែលឈរកាន់ប្រដាប់ថតទាំងភ័យស្លេកមុខគេរអ៊ូតិចៗ ។

- អូនស្អប់បងហើយមែនទេ ? ពេលមុនឃើញបងអូនរត់មក រកបងឥឡូវអូនរត់ចេញឆ្ងាយ !

វីយរុទ្ធ សំឡឹងស្រីល្អឥតព្រិច ដោយការចាប់អារម្មណ៍ :

- សុំទោសអ្នកនាងឈ្មោះអីដែរ ? អ្នកនាងពិតជាមានមុខ

មាត់ដូចអ្នកនាងម៉ាឡា សង្សារបស់អ្នកប្រុសខ្ញុំមែន ! អ្នកប្រុសខ្ញុំទើបនឹងខូចខួរក្បាលមួយឆ្នាំនេះទេ !

ស្រីល្អបំព្រងមានចរិតឆ្មើងឆ្មៃបន្តិច នាងជ្រួញចិញ្ចើម :

- ខ្ញុំជាកូនស្រីឯកអគ្គរដ្ឋទូតខ្មែរណា ! ពុំមែនជាម៉ាឡាសង្សារអ្នកណាទេ !

រជ្ជកាលនៅតែឈរភាំងសំឡឹងមុខស្រីតូច ទឹកមុខគេដូចជាសប្បាយជួនដូចជាព្រួយ !

- ទេ ! ពួកឯងកុំធ្វើបាបនាង ! កុំ.....!

រជ្ជកាលស្ទុះមកទាត់ភ្នាក់ងារម្នាក់ ដែលស្លៀកពាក់ស៊ីវិលប៉ើងដូចស្បូវកណ្តប គេចេញក្បាច់ប្រយុទ្ធស្អាតណាស់ ទាត់តំរង់ភ្នែកវ៉ៃយរុទ្ធតែគេកន្ត្រាក់កងខ្សែដែលជាប់និងជើងរជ្ជកាលអស់ទំហឹង មាណពភ្លាត់ចំណាប់ដួលបះជើង ភ្នាក់ងារបួននាក់ទៀតហក់សង្គ្រប់ចាប់រជ្ជកាលជាប់ក្រញ៉ង់ វ៉ៃយរុទ្ធធ្វើសញ្ញាឱ្យយករជ្ជកាលចូលឡានវិញ។

ភ្លាម១ នោះយុវជនសង្ហាម្នាក់ស្លៀកខូវប៊យរិបរាង ដៃកាន់កំប៉ុងទឹកក្រូចរណោងរណោងរត់មករកស្រីស្រស់នោះ :

- អូនតា មានរឿងអីហ្នឹង ?

មាណវីបួញមាត់ :

- តាប៉ិនោះខូចខួរក្បាល ! គេច្រឡំអូនថាជាសង្សាររបស់គេ !



- យី ! មកច្រឡំគូដណ្តឹងរបស់បងផង កុំតែនឹកថាមនុស្សឆ្កួតបែបបានបែកម៉ាត់ហើយ..... វ៉ៃយរុទ្ធជ្រួញចិញ្ចើម :

- អ្នកប្រុសខ្ញុំ ខូចសរសៃប្រសាទមែន តែជាអំបូរខ្ពស់ម្នាក់លោករៀននិយាយឱ្យបានពិរោះស្តាប់បន្តិចទៅ តិចថាបែកមាត់ខ្លួនឯងវិញ !

ប៊ីដា កញ្ញារូបស្អាតទាញដៃគូដណ្តឹង :

- តោះបងយូគី ! កុំរវល់និងរឿងឥតបានការ ទៅជួលអូប៉័រជិះលេងវិញ !

យូគីជាកូនប្រុសច្បងរបស់លោករដ្ឋមន្ត្រីក្រសួងឃោសនាការពួកគេសុទ្ធតែអំបូរខ្ពស់១ដូចគ្នា ហើយគូដណ្តឹងដែលចាស់១ទុកដាក់តាំងពីតូច១មកទៀតផង។

ប៊ីដាបោះជំហាននាំរាងល្វតល្វន់ដូចកិន្នរចេញទៅ ទុកឱ្យរជ្ជកាលអន្ទះសារម្នាក់ឯង :

- ម៉ាឡា.....អូនស្អប់បងហើយ ហេតុអ្វី ? រឺខឹងនឹងបងខ្វះសមត្ថភាពការពារអូន ? មែន ! ប្រាកដជាអញ្ចឹងមែនហើយ !

រជ្ជកាលស្រែកទាល់តែសន្លប់បាត់ស្មារតី ព្រោះខួរក្បាលកំរើកខ្លាំងពេក។

នៅលើពូកសក្បុស ក្នុងបន្ទប់កញ្ចក់ មាណពដេកស្តូកស្តឹង

លោកកាលីអង្គុយក្បែររ៉ៃគ្រជាមួយវ៉ៃយរុទ្ធ លោកដុកទ័ររ៉ូឌី កំពុងចាក់ថ្នាំជំនួយស្មារតីដល់មាណព :

- ខួរក្បាលគេកំពុងវិលវល់តែសរសៃប្រសាទកំពុងធ្វើការជាកត្តាល្អទៅវិញទេលោកស្នងការ !

លោកការីសែនរីករាយ :

- អាចសង្ឃឹមជាដូចដើមវិញទេ លោកដុកទ័រ ?

- ប្រហែលអាចជា កាលណាមានវត្ថុអ្វី ដែលអាចធ្វើឱ្យចិត្តគេរំភើបដល់អតីតកាល !

លោកកាលីងក់ក្បាលតិចៗ លោករ៉ូឌីត្រឡប់ទៅវិញហើយលោកស្នង ការប្រែទឹកមុខម៉ឺងម៉ាត់ :

- វ៉ៃយរុទ្ធ ឯងឃើញនាងប៊ីដានោះច្បាស់ហើយឬ ?

- បាទ ! ដូចណាស់ បើសិនជាម៉ាឡាមិនស្លាប់នៅនឹងមុខយើងទេខ្ញុំក៏ចាប់ច្រឡំដែរ ! ដូចបេះដាក់តាំងពីអាយុឡើងទៅ !

លោកកាលីក្រពាត់ដៃ :

- ចង់កូនរដ្ឋទូតក៏ដោយ យប់នេះនាំគ្នាទៅយកប៊ីដាមកទីនេះឱ្យបានជាសំងាត់បំផុត រដ្ឋកាលជាវត្ថុដ៏មានតម្លៃសំរាប់ខ្ញុំ ទោះត្រូវប្រើមធ្យោបាយបែបណាក៏ដោយអោយតែគេបានជាដូច ដើមវិញខ្ញុំធ្វើទាំងអស់ !

វ៉ៃយរុទ្ធអោនគោរព :



- កុំព្រួយលោកម្ចាស់ ត្រឹមនាំខ្លួននាងក្រមុំនោះ គ្មានពិបាកអ្វីទេ !

- ល្អណាស់ ! លៃយ៉ាងណាឱ្យស្ងាត់បំផុត !

..........................................................................

ប៊ីដា កំពុងអង្គុយទល់មុខយូគី នៅក្នុងភោជនីយដ្ឋានសុខាល័យយូគី លើកទឹកក្រូចផឹក ភ្នែកផ្តោតលើវង្ង់មុខដ៏ល្អរបស់នាងក្រមុំដោយខ្មាញ់លាយស្រឡាញ់ពេញក្នុងដួងចិត្ត :

- ប៊ីដា រស់នៅហុងកុង២ឆ្នាំគត់ តើអូនយល់យ៉ាងណាដែរពីទិដ្ឋភាពនៅទីនោះ ?

ក្រមុំស្រស់ញាក់ស្មា :

- អូនទើបត្រឡប់មកមាតុភូមិបាន១០ថ្ងៃមែន ប្រទេសគេលើសយើងតែត្រឹមសម្បត្តិផលនានានិងផ្ទះដែលធំស្កឹមស្កៃ ! ឯទេសភាពនិងធម្មជាតិដ៏បរិសុទ្ធ គឺចាញ់ប្រទេសខ្មែរទៅវិញទេ !

- ចុះមនោសញ្ចេតនា ស្នេហាវិញ ?

ប៊ីដាសើចលាយអៀន :

- អូនដើរគ្រប់ប្រទេស តាមលោកប៉ា ក៏ពិតមែនតែប៊ីដា នៅតែមានលក្ខណៈជានារីខ្មែរ ដែលគោរពការទុកដាក់របស់ឪពុកម្តាយដដែល !

យូគីស្រវាចាប់ដៃស្រីទាំងអរព្រួច :

- បងពេញចិត្តនឹងសំដីរបស់អូនណាស់ បីខែទៀត យូរអើយ សែនយូរ !

បីដា ដកដៃចេញក្របួចមាត់ :

- ទីនេះជាហាងមិនមែនជាផ្ទះរបស់បងទេយូគី...!

- សុំទោស...! បង...!

ស្រីស្រស់លើកកែវទឹកក្រូចក្រេបបែបហី :

- គេថា ចិត្តស្នេហ៍ស្មោះលះបង់ដល់ជីវិត ក៏ពុំស្ដាយ អូនដូចជាពុំជឿសោះថា បងយូគីស្រឡាញ់ស្នេហាជាងជីវិត !

- កុំនិយាយអញ្ចឹង បងស្រឡាញ់អូនស្ទើរតែបាត់មុខមិនបានទៅហើយ !

នាងក្រមុំសើចញឹម១ បីដាជានារីម្នាក់ឆ្លាតវៃណាស់ ចេះគ្រប់ភាសា ព្រោះនាងទៅតាមឪពុកប្រចាំការគ្រប់ស្ថានទូតបរទេស នាងបែកពីយូគីទៅនៅស្ថានទូតហុងកុងតាំងពីអាយុ១៣ឆ្នាំ ពេលបានជួបគ្នាក្នុងពេលថ្មី១នេះ នាងក្រមុំសំគាល់ថាយូគី ដុកទ័រសំបូរស្នេហ៍មានមិត្តនារីរាប់មិនអស់ សំរាប់យុវវ័យរបស់គេ តែពេលឃើញសំរស់របស់នាងភ្លាមគេក៏ងាកមករកនាងភ្លាម មិនមែនត្រឹមតែតាមឪពុកម្ដាយទេ ចំណែកបីដាវិញ នាងធម្មតាណាស់សំរាប់ស្នេហា ព្រោះគ្មានអនុស្សាវរីយ៍ចងចាំទុក ។



យូគី សុំខ្លួនជូននាងដើរលេងគ្រប់កន្លែង នាងក៏យល់ព្រមតាមបំណងចាស់ៗ ។

ស្រស់ធីតាសំឡឹងចំភ្នែកគូដណ្ដឹង :

- តាមយោបល់របស់ខ្ញុំ ៣ខែទៀតរៀបការ ដូចជាឆាប់ណាស់ ព្រោះខ្ញុំមើលចិត្តបងមិនទាន់សព្វជ្រុងជ្រោយនៅឡើយ !

- អ៊ំា ! អូនកំពុងចាត់ទុកស្នេហានៃអាពាហ៍ពិពាហ៍ស្មើនឹងស្នេហាអារ៉ាត់អារាយមួយចំនួនខ្លះនោះឬ ?

- ស្នេហាក្នុងការទុកដាក់ វាជាស្នេហាត្រឹមត្រូវហើយ តែក្នុងករណីពិសេសខ្លះ អូនមិនចង់ឱ្យគេរិះគន់ថា លោកដុកទ័រយូគីជាប្រុសខិលខូចទេ ក្រោយពេលរៀបការបងត្រូវរក្សាចំណុចនេះឱ្យបាន !

យូគីក្រហមមុខ :

- មានគេប្រាប់ថា បងខិលមែនទេ ?

- ពុំអាចលាក់ជិតពីមនុស្សរាប់រយពាន់ទេ នារីពេទ្យប្រហែលជាត្រូវខកចិត្តច្រើនណាស់មើលទៅ !

- បីដាសំរាប់អូន ! បងបំភ្លេចអស់បុប្ផានានា ! យូគីស្រឡាញ់តែអូនម្នាក់ ជាអនាគតកុំរាប់បញ្ចូលនារីរាយរងទាំងអស់នោះ ជាមួយរូបអូនអី !

- តែខ្ញុំមិនសូវចូលចិត្តអោយប្ដីរបស់ខ្ញុំ ចាត់ទុកស្រីជាល្បែងទេ ព្រោះខ្ញុំក៏ជាស្រីម្នាក់ដែរ !

- បងនឹងលះបង់និស្ស័យទាំងអស់ ដែលមិនសមភ្នែកប៊ីដា ជឿចិត្តបងចុះ បងស្រឡាញ់អូនណាស់ !

នាងល្អញញឹមស្រាល លើកនាឡិកាមើល :

- ម៉ោង ៨ យប់ហើយ យើងត្រឡប់ទៅផ្ទះវិញ !

- តោះអូន !

កម្លោះក្រមុំបណ្ដើរគ្នាត្រសងតំរង់ឡាន ម៉ាកអូស្ដាំងថ្មីស្រឡាង! មកដល់ផ្លូវព្រះច័ន្ទពេញវង់វៀងស្ងាត់ ឡានមួយបើកអែបឡានយូគី កាំភ្លើងឥតសូរបាញ់តំរង់កង់ឡាន បែកធូរស្ដេត ឡានក្រវីពេញថ្នល់ ធ្វើឱ្យស្រីប៊ីដាភិតភ័យជាខ្លាំង ព្រោះដឹងហេតុការណ៍មិនស្រួលស្រីស្ទុះចុះពីលើឡាន តែស្រមោលខ្មៅជាច្រើនព័ទ្ធជុំវិញយូគីត្រូវលើកដៃព្រោះកាំភ្លើងផ្ទីបចំសៀតផ្ការបស់គេបាត់ទៅហើយ បុរសបិទមុខទាំង ៧នាក់ជាមនុស្សពិសេសរបស់លោកកាលីសុទ្ធតែដៃឆើត មនុស្សដំឡូងមូលដូចយូគីធ្វើម៉េចតបតបាន វ៉ៃយុទ្ធចាប់ខ្ទប់មាត់ប៊ីដាបីដាក់ឡាន នាងក្រមុំរើកញ្ច្រោលទាំងភិតភ័យ :

- បង...! ជួយអូនផង...!

យូគីខ្លាចចុងកាំភ្លើង រួញខ្លួនមិនហ៊ានងើបមុខផងកុំថាដល់ជួយប៊ីដាស្រីល្អសែនខ្ទាញ់ខឹងទាល់តែស្រក់ទឹកភ្នែកខឹងនិងប្រុសកំសាកអួតបានតែមាត់ វ៉ៃយុទ្ធអុកមួយកាំភ្លើងចំកយូគីដួលសន្លប់ស្ដូកស្ដឹងរួចបញ្ហា :



- មិនបាច់សម្លាប់ទេ ឆាប់នាំគ្នាចេញដំណើរ !

ប៊ីដាត្រូវគេចងមាត់ចងដៃជាប់នាំចូលទៅដាក់ក្នុងបន្ទប់កញ្ចក់ជាមួយរដ្ឋកាល ។

ស្រីល្អភ័យណាស់ គ្រាន់តែគេស្រាយចំណងភ្លាមស្ទុះថយសឹងបាក់ក :

- ហ៊ឹះពួកឯងត្រូវការអីពីខ្ញុំ ? ប្រាប់មកលុយកាក់ ឬមាសប្រាក់ ?

វ៉ៃយុទ្ធសើចស្ងួត :

- លោកម្ចាស់ត្រូវការឱ្យអ្នកនាងរស់ក្បែរកូនប្រុសរបស់គាត់ ពីព្រោះអ្នកនាងមានមុខមាត់ដូចសង្សារអ្នកប្រុសណាស់ ពួកយើងគ្មានត្រូវការមាសប្រាក់អីទេ !

ប៊ីដាខាំមាត់សំឡឹងមើលទៅរដ្ឋកាល ដែលដេកស្ដូកស្ដឹងលើគ្រែមុខមាត់ស្រម៉ូមដូចមនុស្សព្រៃធ្វើឱ្យនាងខ្លាចយ៉ាងខ្លាំង ស្រីយំហ៊ូតែម្ដង :

- ទេ ! ទេ ! ខ្ញុំមិននៅជាមួយមនុស្សឆ្កួតទេ !

វ៉ៃយុទ្ធបិទទ្វារកញ្ចក់ជិត នាងល្អរត់ឆ្វេឆ្វាតែម្នាក់ឯង លោកកាលីឈរដក់ខ្សៀក្រៅបន្ទប់យ៉ាងមានអំណាច :

- នាងត្រូវរស់នៅកំដររជីវិតរដ្ឋកាល រហូតនៅទីនេះ ! បើកូនប្រុសខ្ញុំជា ទើបនាងអាចត្រឡប់ទៅផ្ទះវិញបាន !

ប៊ីដាទះទ្វារកញ្ចក់ ដោយកំហឹងតែមិនបែកសោះ ព្រោះកញ្ចក់នេះក្រាស់ណាស់ ជាបន្ទប់សំងាត់របស់លោកកាលី ពុំមែនជាវត្ថុល្មមៗអាចបំផ្លាញបានទេ :

- លែងខ្ញុំទៅវិញទៅ ! លោកជាអ្នកណា ? កូនលោកឆ្កួតចង់ឱ្យគេរស់នៅឆ្កួតតាមកូនលោកឬ ?

លោកកាលីសើចស្ងួត :

- ខ្ញុំហ៊ានធ្វើអ្វីៗទាំងអស់ ដើម្បីឱ្យរដ្ឋកាលជា ពុំមែនត្រឹមបង្ខាំងរូបនាងនោះទេ ទោះត្រូវសម្លាប់មនុស្ស១០០០នាក់ដូចអង្គុលីមារក៏ខ្ញុំធ្វើដែរ ! ចង់មិនចង់នាងត្រូវតែរស់នៅក្នុងបន្ទប់កញ្ចក់ជារៀងរហូត !

គំនិតខុសបែបបទនេះធ្វើឱ្យប៊ីដាយំសស៊ីក ព្រោះគ្មានផ្លូវដោះ-ស្រាយលោកកាលីបង្ខិលខ្លួនចេញពីទីនេះ តែលោកចាត់សហការីទាំង៧រូបឃ្លាំមើលការប្រែប្រួលរបស់រដ្ឋកាលជានិច្ច ។

ពាក់កណ្តាលអធ្រាត្រ មាណពថ្ងូរតិចៗ ដឹងខ្លួនពីថ្នាំងងុយដេកដែលគេចាក់ឱ្យនាយបានសំរាកស្រួល អ្នកកម្លោះងើបអង្គុយឆ្ងក់ ប៊ីដារត់ពីកៅអីបង្អែកទៅឈរកៀនជញ្ជាំង នាងពុំងហ៊ានដេកមួយស្រលេតទេ ព្រោះខ្លាចរដ្ឋកាលពេក ។

អ្នកកម្លោះអង្គុយផ្ទឹងសំឡឹងស្រីល្អ ដែលឆ្លេឆ្លារកផ្លូវរត់ដោយភ័យខ្លាច ! មាណពងើបឈរយឺតៗបោះជំហានទៅរកនាងក្រមុំ :



- ម៉ាឡាហេតុអីក៏អូនស្អប់បង ? បងនឹកអូនណាស់ ! បងនៅតែម្នាក់ឯង ព្រួយច្រើនបែបយ៉ាងណាស់ ព្រោះតែគ្មានអូន ឥឡូវមកដល់ហើយម៉េចធ្វើព្រងើយដាក់បងអញ្ចឹង ?

- ទេ ! កុំមកជិតខ្ញុំ.....ខ្ញុំមិនមែនម៉ាឡា របស់អ្នកឯងទេ !

រដ្ឋកាលស្រវាអោបប៊ីដាជាប់ នាងគក់ក្តិចខ្វាំគេ ដាច់សាច់ទាំងដុំៗ :

- លែង...លែងខ្ញុំ...!

បែបឈឺដែរកម្លោះខូចសតិលាដៃពីប្រាណដ៏មានសំរស់ ក្តោបក្បាលខ្លួនឯង :

- បងមិនយល់ហេតុអី អូនស្អប់បង ហេតុអីទៅ ?

ខ្លួនគេដាច់ឈាមរីមៗរដ្ឋកាលរត់ទៅអង្គុយឆ្ងាយពីប៊ីដា ភ្នែកគេលួចមើលមកនាងល្អ ពេលស្រីក្រលេកចំភ្នែកគេ នាងស្ទុះថយក្រោយរដ្ឋកាលខ្ទប់ភ្នែកយ៉ាងរហ័សលែងហ៊ានដើរមកជិតនាងទៀត កម្លោះក្តោបក្បាលទៅលើពូក វាចាដោយរវើរវាយ :

- ពួកគេធ្វើបាបអូនណាស់ បងខ្វះសមត្ថភាពមិនសមមានឈ្មោះថាជាសង្សាររបស់អូនទេ ! អ្នកម៉ែ...ទេ ! ខ្ញុំមិនមែនជារដ្ឋកាលទេ ! ខ្ញុំគឺខ្ញុំ...!

ប៊ីដាយំសស៊ីកម្នាក់ឯង មិនគួរមករងទុក្ខទោសជាមួយមនុស្សឆ្កួតបែបនេះសោះ ។

ព្រឹកព្រលឹមនាងល្អអស់កម្លាំងល្វើយ ព្រោះអត់ងងុយ ស្រីត្រូវ

តែទទួលបាយទឹកនំចំណី ដែលវ៉ៃយរុទ្ធបញ្ជូលតាមបង្អួចស្វ័យប្រវត្តិមកញ៉ាំ ខោអាវដេកជាច្រើនកំប្លេមានស្រេច មាណវីឃើញរដ្ឋកាលអង្គុយធ្មឹងគ្មានគិតបាយទឹកអ្វីសោះ !

ស្រីចូលក្នុងបន្ទប់ទឹកងូតទឹកផ្លាស់ខោអាវចាស់ចេញសិនព្រោះវាធុំញើសស្អុះស្អាប់ ។ ចេញមកវិញឃើញស្រីបំរើម្នាក់ចូលមកបញ្ចុកបាយឱ្យរដ្ឋកាល តែអ្នកប្រុសគិតតែពីដេក :

- ថយចេញទៅ ពួកឯងបង្ខំមនុស្សឱ្យពិបាករស់មែនទែនតែម្តងបើបាយដូចបាយជ្រូក ទឹកដូចទឹកឈាមអ្នកណាផឹកកើត ?

លោកកាលី អង្អែលពុកមាត់ឈរមើលពីក្រៅជាមួយវ៉ៃយរុទ្ធ :

- គេនិយាយរៀបរយបានច្រើនជាងមុន រដ្ឋកាលជាក្តីសង្ឃឹមក្នុងជីវិតខ្ញុំហើយ !

ប៊ីដាជាអ្នកដាស់អារម្មណ៍គេបានមែន ទេវតាមានភ្នែកបានឱ្យមនុស្សពិសេសបែបនេះមកជួយជីវិតរដ្ឋកាលហើយ !

# វគ្គទី២

# អ្នកលេងសំឡេងឯក

លោកប៊ីណារ៉ានិងអ្នកស្រីឯណោះកំពុងកើតទុក្ខ រឿងបាត់កូនស្រីតែមួយបណ្តូលចិត្ត យូគីអង្គុយជ្រប់មុខក្បែរលោករិនយូ ។

- លោកប៉ា ពួកចោរទាំងនោះ សុទ្ធតែបិទមុខ ខ្ញុំមិនអាចកត់ចំណាំបានទេ វាវាយខ្ញុំសន្លប់ចាប់អូនដាយកទៅ ចិត្តខ្ញុំសែនស្មុគ្រ-ស្មាញ ពុំមែនខ្ញុំព្រងើយកន្តើយទេ !

លោកស្រីប៊ីណារ៉ាយំសសឹក :

- ប៉ាវ៉ា ! យប់ទៅហើយ ពុំដឹងកូនស្រីខ្ញុំវេទនាយ៉ាងណាទេខ្ញុំមានកូនតែមួយ !

លោករដ្ឋទូតលួងលោមភរិយា :

- ខ្ញុំប្តឹងលោកអធិការចក្រីរួចហើយ កម្លាំងភ្នាក់ងារចំរុះគេកំពុងប្រឹងប្រែងហើយណាអូន ! កុំព្រួយពេកប្រយ័ត្នទៅជាឈឺចំណែកយូគីមានគំនិតបែបណា ក៏ខ្ញុំមិនទើសទាល់ដែរ បើយល់ថាកូនប៊ីដាមិនសមរម្យមិនបាច់រៀបការក៏បាន !

យូគី ឧទានតិចៗ :

- ខ្ញុំគ្មានគំនិតបែបនេះទេលោកប៉ា ! គឺខ្ញុំទេដែលខ្វះសមត្ថភាពការពារអូនដា! នាងមានគ្រោះថ្នាក់ពេលទៅជាមួយខ្ញុំដូច្នេះ ខ្ញុំក៏ជាអ្នកមានចំណែកទទួលនូវការភ្លាំងភ្លាត់របស់នាង ខ្ញុំនៅតែពេញចិត្តនាងជានិច្ច !

- ល្អណាស់ ! អញ្ចឹងឯងជួយមើលតាមរង្គសាលខ្លះៗទៅកូន ក្រែងកត់សំគាល់អាជើងខូចទាំងនោះបានខ្លះ !

- បាទ !

.......................................................................

លោកស្នងការកាលី អោយគេហៅលោកអធិការចក្រីមកជួប! ចក្រីជាបុរសស្ថិតក្នុងវ័យ២៧ឆ្នាំមុខស្រស់សំបុរស្រអែម សក់អង្កាដីរូបរាងសង្ហាសមនិងឯកសណ្ឋានភ្នាក់ងារ បណ្ដាស័ក្តនេះណាស់ តែទឹកមុខចក្រីស្ងប់ស្ងួតបង្កប់ទុក្ខព្រួយអាថ៌កំបាំងច្រើន លោកកាលីផ្ញើសញ្ញាឱ្យអធិការក្មេងអង្គុយចុះ :

- យ៉ាងម៉េចទៅហើយ ការងាររបស់លោក ដូចជាចុះថយទឹកដៃសំបើមណាស់ ឥឡូវអធិការដៃដែក ដែលគេប្រដូចទៅនឹងកំហែងរាជសីហ៍មួយគូត្រូវអន់ថយឥទ្ធិពលអស់ ចាប់តាំងពីយើងបាត់បង់សូវង្ស ឥទ្ធិពលជនខិលខូចរីកដុះដាលទ្វេរឡើង ក្រុមចោរសញ្ញានាគសាបព្រួសវិនាសកម្មគ្រប់កន្លែងគ្មានញញើត ខ្ញុំចង់អោយចក្រីឯងស្វែងរកមនុស្សដែលមានស្នាដៃល្អដូចសូវង្ស មកជួយធ្វើការបើមិនដូច្នេះទេ កិត្តិយស



ក្រុមសំងាត់ត្រូវថយដុនដាបសម័យយើងនេះតែម្តង ! ចក្រីបន្ទរដង្ហើមធំអោនគោរព :

- ខ្ញុំមិនអស់ចិត្តសោះ ពីការបាត់បង់ជីវិតរបស់សូវង្ស គ្មានគេរាជសីហ៍មួយគូដូចបក្សីគ្មានស្លាបអញ្ចឹង !

ពួកខ្ញុំតែងធ្វើការអ្វីពីរនាក់រហូត តាំងពីនៅជាភ្នាក់ងារតូចតាចរហូតដល់ទទួលការខុសត្រូវទូទាំងប្រទេសជីវិតសូវង្ស និងខ្ញុំចងជាប់គ្នាជាមិត្តរួមអាវុធហើយនិងមិត្តរួមជីវិតថែមទៀត គេធ្លាប់និយាយថាបើខ្ញុំស្លាប់ទើបគេស្លាប់ពេលនេះខ្ញុំ នៅរស់ទេហេតុអីក៏គេស្លាប់ចោលខ្ញុំ ? ពួកនៅទល់ដែនខ្លាំងក្លាមែន ដែលវាអាចប្រឡេះសូវង្សឱ្យឃ្លាតឆ្ងាយពីខ្ញុំថាខ្ញុំមាន មនោសញ្ចេតនាដូចស្រីក៏បានដែរ សព្វថ្ងៃខ្ញុំនឿយណាយ និងការងារអស់ហើយ ! កុំតែនៅមានគំនុំឈាមមួយដែលត្រូវទាមទារឱ្យមិត្តរួមជីវិត ម្ល៉េះខ្ញុំដោះសក្តិជូនលោកស្នងការវិញបាត់ទៅហើយ !

លោកកាលី គោះតុមួយៗ :

- បើលោកលាលែងទៀត ខ្ញុំក៏ត្រូវតែសំរាកដែរ ធ្វើការម្នាក់ឯងទៅមិនរួចទេ ! ឯភ្នាក់ងារភារកិច្ចជំនាន់ថ្មី រកអ្នកទុកចិត្តមិនទាន់បានសោះ !

- ចោរទល់ដែនកំពុងតែលាតសន្ធឹងសញ្ញានាគប្លន់អស់ថៅកែធំៗច្រើនយើងសំបើមណាស់ គេជាសត្រូវធំនៃការបាត់បង់សូវង្ស ! បើ

ខ្ញុំបំផ្លាញពួកវាមិនបាន ខ្ញុំក៏លាលែងដំណែងដែរ នៅពេលណាដែលខ្ញុំសារភាពថា អស់លទ្ធភាព !

- សុំឱ្យបំណងឯងបានសំរេច តែកុំអាលមើលងាយមេចោរនាគខ្មៅឱ្យសោះ ! កុំភ្លេចថាសូវង្សអធិការដៃដែកទៅហើយ នៅតែភ្លាត់ស្នៀត !

- បើចាញ់គ្រាប់កាំភ្លើង គឺហ៊ានស្លាប់ គ្មានអ្វីដែលខ្ញុំត្រូវខ្លាចជាងសេចក្តីស្លាប់ទេ បើពាក្យស្លាប់ឥតចាំបាច់ទៅហើយ ! មនុស្សនិងមានសេចក្តីក្លាហាន និងធ្វើអ្វីគ្រប់យ៉ាងឱ្យបានសំរេច !

លោកកាលីសើចញឹម១ :

- ខ្ញុំពេញចិត្តនិងសេចក្តីក្លាហានរបស់លោកណាស់ អូ ! លឺថាលោករដ្ឋទូតមកប្តឹងបាត់កូនស្រីឬ ?

- បាទ ! ខ្ញុំកំពុងចាត់ភ្នាក់ងារតាមដានរឿងនេះ !

លោកកាលីនៅស្ងៀម ទៅរកឯណា បើបីដានៅក្នុងបន្ទប់សំងាត់របស់លោកឯណោះ លោកបំពានលើមុខងារខ្លួនឯងសំបើមណាស់ ព្រោះតែជីវិតកូនប្រុសរបស់លោកវាមានអត្ថន័យធំជាងបុណ្យសក្តិ !

អធិការក្មេងកំពុងអង្គុយពិនិត្យសំណុំរឿង ក្នុងបន្ទប់ការងារផ្ទាល់ សំឡេងហួចលីពិរោះគ្រលួចមានន័យស្រឡាញ់ពន្លឺនៃព្រះអាទិត្យធ្វើឱ្យចក្រីរអ៊ូតាំងពីទ្វារមិនទាន់បើក ។

- មកទៀតហើយ ចំជាអស្ចារ្យមែនអាល្អិតនេះ ! ទ្វាររបើក



លេចរូបភ្នាក់ងារពីររូបបណ្តើរកម្លោះរូបស្អាតម្នាក់ចូលមក ពិតជាទេវបុត្រនៃសំរស់មែន ! វង្ងង់មុខគេស្អាតអស្ចារ្យណាស់ ភ្នែកខ្មៅដូចនិលច្រមុះស្រួច បបូរមាត់ព្រែកញញឹមស្រស់សាច់មុខ ម៉ដ្តដូចស្រីក្រមុំអាយុ២៤ឆ្នាំយ៉ាងច្រើន ស្លៀកខោចៃវពក្លាក់អាវហោប៉ៅបីជ្រែងជាប់ដូចអ្នករស់នៅប៉ែកសមុទ្រអញ្ចឹង សក់ទុកលុបត្រចៀកអាវចំហឡេវពីរ បង្ហាញខ្សែខ្មៅពាក់ជំនួសខ្សែកដាក់បន្តោង ក្រចកខ្លាតែស្រោបមាសសុទ្ធ និយាយរួមរូបរាងគេស្អាត រកប្រុសណាមកធៀបស្មើពុំបានតែការតុបតែងខ្លួនជារបៀបអ្នកលេងដែលរស់ តាមសំយ៉ាបផ្សារទៅវិញ ចក្រីគំហកឱ្យ :

- វាតា ! ឯងដូចជាព្រហើនពេកហើយ ការយោគយល់របស់ខ្ញុំវាមានព្រំដែន ! កុំអាងពេកមើលឯងគិតចូលគុកប៉ុន្មានដង ក្នុងមួយខែ ?

កម្លោះរូបស្អាតដែលមានឈ្មោះថាវាតា សើចស្រស់ទាញកៅអីអង្គុយទល់មុខលោកអធិការក្មេង :

- អីយ៉ា ! កាចណាស់តើ ឥឡូវស្រេចលើយោបល់លោកទេ !

ខ្ញុំស៊ីផឹក ព្រោះក្រពះវាទាមទារ ដល់អត់លុយសងគេសុខចិត្តដើរចូលគុក ដើម្បីសងជម្ងឺចិត្តចៅកែហាង ទោសកំប៉ិចអញ្ចឹង បើលោកយល់ថា ចាំបាច់ត្រូវតែឆក់ខ្សែភ្លើងសួរចំលើយ ក៏ស្រេចតែលោក ព្រោះលោកមានសិទ្ធនៅទីនេះ !

ចក្រីហួសចិត្ត ៖

- បើអត់លុយណាស់ ច្រៀងតាមផ្លូវចូលទៅផ្សារ ក៏មានអ្នកដាក់ទានដែរ គ្រាន់បើជាងឯងមកច្រៀងតំឡង់គេនៅក្នុងគុកដែរ !

វាតា សើចកក្អឹក ៖

- ខ្ញុំអត់ផ្ទះនៅដេកតែលើកៅអីក្នុងសួនច្បារប៉ូលីសដេញរំខានណាស់ ! បានចូលកន្លែងលោកមានបន្ទប់មានដំបូលស្រាប់មានអ្នកយាមឆ្វេងស្តាំមើលទៅប្រហែលរដ្ឋមន្ត្រីដែរ បានជាខ្ញុំមិនដាច់ចិត្តទៅណាចោលលោកអធិការ !

ចក្រីសើចស្ងួត ៖

- អ្នកខ្លះគេសរសើរឯងថា អ្នកលេងចិត្តជា អ្នកខ្លះគេថាឯងដើរជួយបំពេញកិច្ចការគេគ្រប់មុខដើម្បីប្រាក់ ! ហេតុនេះមិនសមឯងគ្មានលុយឱ្យថ្លៃស្រាសោះ ! យើងកំពុងចង់ដឹងថា គោលបំណងអីដែលឯងយកលេសធ្វើ កំហុសឱ្យមានជាបន្តបន្ទាប់ឥតឈប់ឈរ ដើម្បីចូលគុក ?

វាតាអង្រួនជើង បែបប្រហើរ ៖

- លោកអធិការឆ្លាតមែន សមនិងពាក្យគេធ្លាប់សរសើរថានៅទល់ដែនមានក្រញាំនាគ នៅដីកណ្តាលមានរាជសីហ៍មួយគូ ស្តាយដែរមនុស្សដែលខ្ញុំចង់ស្គាល់ស្លាប់មុនខ្ញុំបានជួបទៅវិញ !

ចក្រីស្ទុះងើបដូចខ្សែភ្លើងឆក់ ដោយទឹកមុខប្លែក ៖



- ហ៊ិះ ! ឯងជាអ្នកណា ? ជាដៃជើងនាគខ្មៅមែនទេ ? បានជាឯងដឹងប្រវត្តិនៃពាក្យនេះ !

វាតា សើចបែបហី ៖

- ខ្ញុំកំពុងតែសរសើរថា លោកឆ្លាតឥឡូវចេញក្បួនល្ងង់ មកភ្លាមតែម្តង ! មុននិងចោទខ្ញុំ គួរត្រិះរិះបន្តិចទៅលោកអធិការ បើខ្ញុំជាបក្សពួករបស់នាគទល់ដែនថៃ ខ្ញុំមិននាំខ្លួនមកឱ្យលោកលក់ខ្ញុំទទេៗនោះទេ ! ខ្ញុំដឹងគុណលោកដែលចេះយោគយល់ខ្ញុំចេះអប់រំខ្ញុំឱ្យក្លាយជាមនុស្សល្អ ជាប់គុកកន្លែងលោក ១០ដង អត់មានការប្រមាថអ្វីមួយម៉ាត់ទើបខ្ញុំចង់មកក្រើនរំលឹកលោក ដើម្បីបំណងល្អតែប៉ុណ្ណោះ លោកគួរប្រុងប្រយ័ត្នជាមួយមនុស្សដែលស្ថិតនៅជាមួយលោកទាំងអស់ នាគខ្មៅវាហ៊ានវាតទីតាំងពីទល់ដែនមកដល់ភ្នំពេញ ហ៊ានប្រឡេះលោកអធិការដៃឆើតសូវង្សយ៉ាងអាថិកំបាំង គឺវាមិនមែនជាមនុស្សអន់ឡើយ! បើវាប្រឡេះលោកបានមួយទៀត អ្នកស្លូតត្រង់ច្បាស់ជាអស់ការកក់ក្តៅហើយ !

ចក្រីសំឡឹងមុខកម្លោះរូបស្អាតយ៉ាងមុត ៖

- ឯងនិយាយដូចជាដឹងរឿងនាគខ្មៅច្បាស់ណាស់ មែនទេ ?

វាតាសើចញ៉ីមៗ ៖

- ធម្មតាទេ ! លោកថាត្រូវហើយ វាតាជាជនអាវ៉ាសែរស់តាមសំយ៉ាបផ្សារតាំងពីអាយុ១០ឆ្នាំ ហេតុនេះខ្ញុំស្រឡាញ់ប្រាក់ ខ្ញុំ

ស្រឡាញ់អ្នកក្រដូចខ្ញុំ ជួនកាលខ្ញុំហ៊ានធ្វើការខ្លះៗអោយអ្នកមានប្រាក់ ដើម្បីទិញបាយកញ្ចប់ចែកអ្នកសុំទាន ! អ្នកដែលជួលខ្ញុំ គឺពុំមែនជាជនជំពូកល្អទេ គឺសុទ្ធតែជាមនុស្សដែលមានកិច្ចការលាក់លៀម ឯចំណែកខ្ញុំជាអាជ្ញាកណ្ដាល !

វ៉ាតាសំបូរលុយណែនហោប៉ៅ ដើរប៉ាវតាំងពីក្មេងសុំទាន តែការប្រព្រឹត្តរបស់គេដូចជារកចាប់ចំណុចមិនបាន ថាគេជាមនុស្សរបៀបណាទេ បើនិស្ស័យកំណើតរបស់គេវិញគឺជាមនុស្សរស់នៅក្នុងជីវិតដូចជនហ្វីឡូអញ្ចឹង មិនលោភទ្រព្យមិនគិតប្រយោជន៍ផ្ទាល់ខ្លួន មិនចង់រាប់អានមិត្ត ចូលចិត្តតែដើរទៅណាតែម្នាក់ឯង តែចិត្តទូលាយណាស់ បើនិយាយពីសំឡេងពិរោះរកគ្មាន ស្រែកច្រៀងនៅទីណាក៏មានគេឈរស្ដាប់អោយរហង់បើដេកច្រៀងលើបង់ក្នុងសួនច្បារ ទាល់តែសិស្សសាលាចោមរោមខានរៀន គ្រូៗមកដេញចេញទើបវ៉ាតាងើបដើរទៅបាត់រហូតគេឱ្យឈ្មោះថាអ្នកលេងសំឡេងឯកទៅហើយ ឯបទចំរៀងរបស់គេមានន័យដដែលៗ គឺស្រឡាញ់ពន្លឺព្រះអាទិត្យមុនអ្វីៗទាំងអស់ចក្រីជ្រួញចិញ្ចើមហាក់រិះគិតទៅឆ្ងាយ :

- បានន័យថាឯងមកក្នុងពេលនេះ ដើម្បីគ្រើនរំលឹកខ្ញុំមែនទេ?

វ៉ាតាញាក់ស្មា :

- មិនមែនទេលោក ! ខ្ញុំមកពេលនេះថៅកែហាងគេចាប់មកទេ ជើងប៉ាវគេច្រើនពេក ខ្ញុំខ្ជិលតដៃខ្លាចខាតញើសក៏ព្រមមកទទួលទោស១៥ថ្ងៃតែម្ដងទៅ !



- ឯងមិនទាន់ឆ្លើយសំនួរមួយទៀត ដែលខ្ញុំចង់ដឹងថា ហេតុអីឯងស្រឡាញ់គុកសំបើមម្ល៉េះ? បើមុននេះឯងនិយាយថាមិនចូលចិត្តច្បាប់របស់ខ្ញុំ ?

- លោកអធិការប៊ុនស្នាក់សំដីមែន តែចំលើយរបស់ខ្ញុំនៅតែដដែល គឺកាលណាខ្ញុំមានផ្ទះត្រឹមត្រូវ លោកប្រាកដជាលែងបានឃើញមុខខ្ញុំទៀតហើយ !

- ខ្ញុំមិនទាន់អស់លទ្ធភាពសួរឯងទេ ! តែខ្ញុំទុកឱ្យឯងកុហកសិនចុះ ព្រោះពេលវេលាខ្ញុំពុំមែនសំរាប់សួរតែឯងម្នាក់ទេ ០៧៧ឯងនាំគេទៅរកកន្លែងគួរសមទៅ !

វ៉ាតាញាក់ស្មា :

- គួរសមដែរលោកអធិការ ម៉េចៗទៅសុំនៅបន្ទប់លេខ៤ ហើយកុំនាំចូលកន្លែងពួកឃាតករជាប់ទោសឧក្រិដ្ឋធុំក្លិនអាក្រក់ណាស់ !

- ឯងស្រឡាញ់តែបន្ទប់លេខ ៤ ខ្ញុំបំពេញបាននាំគេទៅចុះ !

វ៉ាតាហួចក្លេវៗ ដូចគ្មានញញើតអ្នកណាទេ តែចក្រីមិនប្រកាន់ឡើយ ជាច្រើនដងដែលអ្នកបានជួបនិងវ៉ាតា អ្នកហាក់មាននិស្ស័យជាមួយអ្នកកម្លោះដ៏ក្មេងនេះ ហើយរកធ្វើបាបគេមិនកើតសោះ ព្រោះចេះតែជឿជាក់ថា គេជាមនុស្សគួររាប់អានម្នាក់ទៅវិញ ឆាកជីវិតគេ

អារាត់អារាយ តែបង្អប់ទៅដោយសេរីភាពក្នុងការរស់នៅ ! ចក្រីតាមមើលដំណើរគេរហូតផុតកន្ទុយភ្នែក ។

រាត្រីស្ងាត់សូន្យ សំឡេងចំរៀងដ៏ពិរោះលាន់លឺរងំ ដោយមិនបាច់មានភ្លេង ផ្អើលអស់អ្នកទោសដែលនៅបន្ទប់ក្បែរនោះ ស្ទុះមកតោងចរឹងបន្ទប់ឃុំឃាំងសួរគ្នាឱ្យលាន់ :

- អេ ! វេតា មកទៀត ហើយឬ ?

- ចុះមាននរណាក្រៅពីលោកក្បាលខូចនឹង !

វាតា សើចកក្អឹក

- ខ្ញុំនឹកពូៗ បានជាខ្ញុំមកទៀតនឹងណាំ !

អ្នកកម្លោះឈរផ្អែកជញ្ជាំង ច្រៀងធ្វើហី....

"រស្មីព្រះអាទិត្យ"

I- សំឡឹងចុងស្មៅតំណក់ឈាមស្រស់ ចង់បំភ្លេចអស់រឿងរ៉ាវអាស្រូវ
បែរមើលទៅជ្រោះទឹកជ្រោះសែនជ្រៅរកស្ពានមិនត្រូវជំរៅចិត្តមនុស្ស
II- ចង់សួរពពកពពកមិនដឹង វាតាស្ងាត់ឈឹងចាំបាត់ចំលើយ
រឿងថ្ងៃមុននោះយ៉ាងណាទៅហើយ រាវរកពាក្យឆ្លើយក្នុងភពវង្វេង!
R- រស់នៅម្នាក់ឯងចំបែងចិត្តណាស់ ថ្ងៃរះមិនច្បាស់បែរងងឹតសូន្យ
ចំណែកការពិតប្រៀបបីដូចក្បូន រលកស្ងាត់សូនក្បូនឆ្ងាយឥតត្រើយ!
III- ដួងចិត្តរំពឹងរងចាំនិស្ស័យ ចិត្តសែនអាល័យតំណក់ឈាមស្រស់
ជើងឈានទៅមុខបំណងប៉ងខ្ពស់ ប្រហារឱ្យអស់ទើបថ្ងៃរះបាន ។



ចំរៀងមានន័យសង្កត់ពាក្យប្រៀបបីដូចមេទ័ព កំពុងបញ្ជាស្មៀតប្រហារ តែសំឡេងស្រទន់ពិរោះពិបាកឱ្យតម្លៃឱ្យបានសមណាស់ពីអត្ថន័យចំរៀងមួយបទរបស់វាតា ! អ្នកទោសលង់លក់ស្ងាត់អស់តែវាតានៅច្រៀងរហ៊ុមតិចៗម្នាក់ឯង ។

ម៉ោង ៩ យប់ទៅហើយ អ្នកយាមមន្ទីរឃុំឃាំងមិនឃាត់វាតាទេ ព្រោះធ្លាប់ដឹងចំណូលចិត្តរបស់កម្លោះនេះទៅហើយ ។

ស្ងាត់មនុស្សក្នុងបន្ទប់ឃុំឃាំងដ៏តូចចង្អៀតនេះងងឹតស្លប់ វាតាងើបក្រោះ ហូតដែកកេះដែលលាក់ក្នុងស្បែកជើងមកកេះមើលជញ្ជាំងមន្ទីរឃុំឃាំង កម្លោះជូតដីដែលហុយប្រលាក់ឡើងខ្មៅលើជញ្ជាំងស្នាមស្រោបតំនួសជាច្រើន គឺតួអក្សរល្អិតៗ វាតាមើលមួយឃ្លាម្តងៗដល់វគ្គក្រោយទាល់តែចាំច្បាស់ ទើបប៉ាតដីដែលជាប់ជញ្ជាំងក្បែរនោះមកលប់លើតួអក្សរឱ្យដូចធម្មតាវិញ មាណពដោះអាវចេញ ចាប់ហាត់តែម្នាក់ឯងក្នុងបន្ទប់ឃុំឃាំង ទាល់តែបែកញើស ជោគទាំងកណ្តាលរាត្រី ម្រាមរបស់វាតា លាចេញពីរថ្កក់ចូលរាងក្រង៉ុក ដូចក្រចកខ្លាបេះបិទហក់សង្គ្រប់ទៅមុខចំកន្លែងមានចារក្បាច់គុណបុរាណ នេះលាន់សន្ធឹកដៃវីបៗ ខ្ទេះស៊ីម៉ង់ត៍ឡើងចេញស្នាមម្រាមក្រឡៅលប់អក្សរខ្ទេច ។ មាណពត្រេកអរណាស់ បង្វិលខ្លួនជក់ដូចកង្ហាទះឡើង ស៊ុះលើជញ្ជាំងបំផ្លាញក្បួនគុនរលប់អស់ ។

- អ្ហ៎ា ! ខ្ញុំហាត់ចេះហើយ ! ១៦ដងទើបរកចំណុចអាថិកំបាំងនៃក្បាច់ក្រញាំខ្លាឃើញ !

វ៉ាតាចាប់លើកបន្ទោងក្រចកខ្លាប្រចាំត្រកូលមកមើល ទឹកមុខសប្បាយរួចបន្សល់នូវភាពជូរចត់ជំនួសវិញ នៅលើផ្ទៃមុខដ៏ស្រស់ដែលជិតដាមដោយដំណក់ញើស កម្លោះសង្ហាលុតជង្គង់ចុះ ឈូសស៊ីម៉ង់ត៍លើជញ្ជាំងរអ៊ូតិចៗ :

- លោកតា ចៅបានបំពេញបំណងលោកតារួចហើយ ឈាមអ្នកលេងត្រូវតែឈ្នះគេជាដរាប ! ស្នូរសិរិបជើងស្រាលស្ទើកដូចស្លឹកឈើជ្រុះ តែត្រចៀកវ៉ាតាចំណាប់ណាស់ ព្រោះគេជាមនុស្សដែលមានសមត្ថភាពខ្ពស់បំផុត ! កម្លោះងាកក្រោយភ្លែត ចក្រីកំពុងឈរទ្រឹងមុខទ្វារទីឃុំឃាំងយុវអធិការសើចស្ងួត ចាក់សោរបន្ទប់ចូលមក :

- ខ្ញុំឃើញអស់ហើយ ខ្ញុំមិនបាច់សួរឯងទៀតទេ ហើយចាប់ពីពេលនេះទៅប្រហែលជាវ៉ាតាលែងមានមុខនៅទីនេះទៀតហើយ ! ខ្ញុំគ្រាន់តែឆ្ងល់ថា ក្បាច់ដែលឯងហាត់នេះជាស្នៀតរបស់អ្នកណាសរសេរទុកនៅទីនេះទៅវិញ ?

វ៉ាតារលាស់សក់តបមួយៗ :

- ស្នៀតក្រចកខ្លា ខ្ញុំហាត់ចេះនិងបំផ្លាញចោលអស់ទៅហើយ ខ្ញុំមិនខ្លាចនិងប្រាប់លោកទេ គឺជាស្នៀតប្រយុទ្ធប្រចាំត្រកូលរបស់ខ្ញុំ ! ២០ឆ្នាំបួយមុនជីតារបស់ខ្ញុំត្រូវសិស្សក្បត់មួលបង្កាច់ចោទថាជាឃាដ-



ករតាមល្បិចនិងអន្ទាក់របស់គេ ជីតាខ្ញុំត្រូវភ្នាក់ងារចាប់ខ្លួនមកឃុំ-ឃាំងនៅទីនេះ វាមិនអស់ចិត្តក្លែងខ្លួនជាភ្នាក់ងារលាយថ្នាំពុល ក្នុងបាយយកមកឱ្យជីតាខ្ញុំទៀត លោកតាស្រេកឃ្លានពេលខ្វះសេរីភាពក៏ហូបបាយនោះ ! ស្នានតែគេចែកជាធម្មតា តែមុននិងស្លាប់លោកតាខ្ញុំបានកាច់បំបាក់ចុងស្លាបព្រាសរសេរគន្លិះស្នៀតសំខាន់ប្រចាំត្រកូលខ្ញុំ ! ដែលសូម្បីតែឪពុកខ្ញុំក៏ហាត់មិនចេះផង ទុកនៅទីនេះ ខ្ញុំនៅតូចទទួលការបែកបាក់ព្រាត់ប្រាស់ពីម្តាយឪពុក ដោយសារអាមនុស្សក្បត់នោះបានតាបំរើនាំគេចខ្លួន គាត់លាក់ខ្ញុំរួចលួចមកសួរសុខទុក្ខលោកតាក្នុងគុកទើបដឹងរឿងគន្លិះហាត់ស្នៀតនេះ គាត់ក៏ខ្ញុំទៅរស់នៅកោះថ្មសកណ្តាលសមុទ្រឯណោះ មុនពេលលោកអុំសារិ ស្លាប់គាត់ប្រាប់ប្រវត្តិពិតដល់ខ្ញុំ ! ខ្ញុំបានមកជាន់ដីគោកនេះដើម្បីតែគោលបំណងនេះឯង ! ជិតមួយឆ្នាំដែលខ្ញុំបានមករស់នៅទីក្រុងភ្នំពេញ ខ្ញុំបានលឺល្បីពីវីរភាពរបស់អធិការសូវង្សនិងរូបលោក ខ្ញុំមានសមានចិត្តចំពោះពួកលោកបំផុត តែសោកស្តាយដោយខ្ញុំ មិនទាន់បានស្គាល់លោកសូវង្សផង គាត់ត្រូវមនុស្សអាក្រក់សំលាប់បាន !

ចក្រីគោះស្មាវ៉ាតាដោយពេញចិត្ត :

- វ៉ាតា ! បើខ្ញុំយល់មិនខុសទេ ឯងជាដុំពេជ្រកប់ក្នុងភក់ជ្រាំជាអំពើល្អក្នុងអំពើអាក្រក់ ខ្ញុំចង់សុំអោយឯងរួមដៃធ្វើការជាមួយខ្ញុំ !

តើឯងយល់យ៉ាងណា ? ឬក៏ពេញចិត្តនៅធ្វើការឱ្យមនុស្សអាក្រក់រហូតទៅដើម្បីប្រាក់រហូតទៅវិញ ?

វ៉ាតាញញឹមស្ងួត :

- មែន ! ខ្ញុំជាមនុស្សតែលតោលសូម្បីតែផ្ទះក៏គ្មាននៅផង បើមិនធ្វើការដើម្បីប្រាក់ លោកគិតឱ្យខ្ញុំដើរច្រៀងសុំទានគេ ដូចពាក្យលោកថាមែនទេ !

ចក្រី អង្អែលពុកមាត់ ដែលគេទុករីម១ :

- ខ្ញុំមានផ្ទះមួយយ៉ាងស្អាតប្រគល់ទុកឱ្យឯង រស់នៅមានលុយសំរាប់ឯងចាយ ហើយចង់ឱ្យវ៉ាតាឯងទាក់ទងមនុស្សខូចដដែល ! តែសុំឱ្យមានភាពស្មោះត្រង់ជាមួយខ្ញុំ ម៉េចប៉ុណ្ណឹងយល់ទេ ?

វ៉ាតា ញាក់ស្មា :

- អូ ! យល់ហើយគ្រោះថ្នាក់ដែរណ៎ា ! បើបែកការណ៍ពួកវាច្បាស់ជាខ្ទេចខ្ញុំ ស៊ីជាមិនខានទេ !

- ខ្ញុំដឹងថា ឯងជាមនុស្សដឹងខុសត្រូវល្អណាស់ ប្រាកដជាយល់ថាត្រូវប្រព្រឹត្តខ្លួនបែបណា ក្នុងនាមជាកូនប្រុសដែលមានសមត្ថភាពពេញខ្លួនដូច្នេះ ! កុំលាក់តំរេះ កុំបំពួនប្រាជ្ញាជួយមនុស្សល្អជាកត្តាថ្លៃថ្នូរណាវ៉ាតា !

- អីយ៉ា ! កំពុងតែបញ្ចោរខ្ញុំហើយ ! ណ្ហើយចាត់ទុកថាខ្ញុំជួយលោកដើម្បីដូរបាយទៅចុះ ! មនុស្សព្រៃដូចខ្ញុំ មិនសូវជាចេះ



ពិចារណាពីអ្វីៗដែលហៅថាឧត្តមគតិទេ ខ្ញុំគ្រាន់តែចង់ស្វែងរកមនុស្សអាក្រក់ម្នាក់ដែលបំផ្លាញគ្រួសារខ្ញុំប៉ុណ្ណោះ ! ខ្ញុំយល់ព្រមរួមដៃជាមួយនឹងលោកទៅចុះ !

ចក្រីអរណាស់ ព្រោះគេជឿជាក់ថា មនុស្សឆ្លាតហើយលាក់តំរេះដូចវ៉ាតានិងក្លាយទៅជាមិត្តរួមអាវុធចេញសាងសន្តិភាព ជូនជនរួមជាតិមិនអន់ជាងកាលសូនីការនៅរស់ឡើយ ! ចក្រីនាំវ៉ាតាចូល ក្នុងបន្ទប់យាមផ្ទាល់របស់គេដើម្បីពិគ្រោះគ្នា :

- អង្គុយចុះសិនមកវ៉ាតា ! កិច្ចការទាំងនេះត្រូវដឹងតែយើងពីរនាក់គត់ !

- ត្រូវតែអញ្ចឹង តែលោកត្រូវប្រុងប្រយ័ត្នបន្តិច សព្វថ្ងៃខ្ញុំស៊ីឈ្នួលយកការណ៍ឱ្យក្រុមចោរនាគខ្មៅណាដឹងទេ ?

ខ្ញុំជាមនុស្សដើរតត្រុកគ្រប់កន្លែង កត់ចំណាំបានស្ថានភាពផ្ទះអ្នកមានគ្រប់ច្រកល្ហក សំរាប់ឱ្យការពួកគេចេញប្លន់នៅចន្លោះពេលល្មមេចោរនោះជាមនុស្សម្នាក់សំបូរកលល្បិចជាទីបំផុត វ័យក្មេងតែខ្លាំងពូកែ សូម្បីតែមុខមាត់ពិតរបស់វា ក៏គ្មានអ្នកណាដឹងផង វាធ្លាប់តែប្លន់នៅតំបន់ទល់ដែន តែឥឡូវហ៊ានមកតាំងទីដល់កណ្តាលក្រុង គឺពិតជាមានខ្នងរឹងមាំណាស់ ។

ចក្រីងក់ក្បាល :

- ខ្ញុំកំពុងតែល្ងឹងមុខនិងបញ្ហានេះ តើវាតាឯងដែលឃើញមុខវាទេ ?

- ជួបពីរដងដែរ នៅពេលដែលវាមកទទួលរបស់ដែលប្លន់បាន តែមុខផ្សេងគ្នារហូតពុំដឹងមួយណាជានាគខ្មៅទេ !

- គ្នាវាច្រើនទេ ?

- តែ១៥នាក់សោះ តែមានស្នាដៃល្អណាស់ ល្មមតែភ្នាក់ងារលោកពីរឡានអីចូលមិនចុះទេ ខ្ញុំបានឃើញច្បាស់ទាំងល្បិចបាញ់កាំ-ភ្លើងឡើងទៅ !

- ចុះវាតាឯងមានសភាពបែបណាចំពោះភ្នែកពួកវា ?

- ខ្ញុំជាមនុស្សសាមញ្ញអត់គួរឱ្យពួកវាចាប់អារម្មណ៍ទេ !

- អូ ! ចាប់ពីពេលនេះទៅ ខ្ញុំចង់ឱ្យវាតាបង្ហាញតិរិះពិតដើម្បីទាញការទុកចិត្តពីវា ! ចង់ចាប់នាគត្រូវចុះឱ្យជ្រៅក្នុងសមុទ្រ !

- ខ្ញុំក៏ដឹងដែរ តែឱកាសមិនទាន់មកដល់ ខ្ញុំមិនទាន់ប្រាកដក្នុងចិត្តថា មនុស្សដែលខ្ញុំត្រូវការ គឺវាឬក៏មិនមែន ខ្ញុំទាក់ទងបំរើការឱ្យពួកនេះក៏ក្នុងវត្ថុបំណងផ្ទាល់ខ្លួនចាំបាច់របស់ខ្ញុំដែរ !

- ទោះវាពុំមែនជាសត្រូវរបស់វាតាឯង ក៏ជាសត្រូវរួមក្នុងសង្គម !

- កុំព្រួយ ! ខ្ញុំនិងជួយលោកឱ្យអស់ពីសមត្ថភាព !

- នេះជារបស់ដែលឯងត្រូវប្រើ សំរាប់ទាក់ទងការងារជាមួយ



ខ្ញុំណេះកាំភ្លើង ហើយនេះអាស័យដ្ឋានផ្ទះលាក់ការណ៍របស់ខ្ញុំ ដែលខ្ញុំប្រគល់ឱ្យឯង !

- អរគុណ លោកអធិការ !

វាតាងើបមុខចំរូបថតតាំងលើតុធ្វើការ បុរសពីរនាក់គ្រងឯក-សណ្ឋានអធិការដូចគ្នា កៀកស្មាគ្នានៅលើម៉ារីនមាត់សមុទ្រញញឹមយ៉ាងមានអំណាចបុរសខាងស្តាំដៃចក្រី មានរង្វង់មុខសែនសមស្អាតហើយសង្ហាណាស់ ភ្នែកមុតមានន័យអង់អាចនិងដាច់ខាត។

វាតាស្ទុះងើបសំលឹងរូបថត ដោយការចាប់អារម្មណ៍ចំពោះមគេជ្រួញចូលគ្នា :

- អាំ ! នេះគឺរូបលោកនិងសូវង្សមែនទេ ?

- មែន ! គឺសូវង្ស ! យ៉ាងម៉េចវាតា ?

កម្លោះខាំមាត់ជាប់ :

- បើខ្ញុំមិនច្រលំទេ នាគខ្មៅមកលើកទី២ គឺមុខមាត់គេដូចសូនីវង្សបេះដាក់អាយុក៏ខ្ទង់២៨ឆ្នាំដូចគ្នាដែរ តើលោកយល់បែបណា?

ចក្រីបើកភ្នែកធំៗ :

- មែនឬ ? ទេ ! ពុំសមសោះលោកសូវង្សជាមនុស្សរបស់ប្រទេសជាតិពុំអាច........

- លោកគួរតែរិះគិតម្តងទៀត ខ្ញុំស្រឡាញ់ន័យចំរៀងរបស់ខ្ញុំជ្រៅជ្រះនៅចាញ់ចិត្តមនុស្ស លោកសូវង្សស្លាប់បែបណា? ជួនកាល

ព្រោះតែកំពូលចោរជាអ្នកដឹងអស់កិច្ចការប៉ូលីស ទើបគេឈ្នះលោក រហូតមួយឆ្នាំមកហើយ លោកចាប់ដៃជើង គេតែម្នាក់ក៏មិនបានដែរ ! កិត្តិយសលោកធ្លាក់ដល់គីរិតណា លោកមានបានគិតដល់ដែរឬទេ ?

ចក្រីខាំមាត់ជាប់ :

- គួរឱ្យចាប់អារម្មណ៍ដែរ ពីព្រោះឆ្នាំមុនគេស្លាប់ដោយពួកចោរនាគខ្មៅគ្រវែងគ្រាប់បែកសម្លាប់ក្នុងឡាន ភ្លើងឆេះរួញក្រញ៉ង់ មើលរូបរាងលែងស្គាល់ ហ៊ុះបើគេក្លាយជាជនបែបនេះ ខ្ទង់ដែលធ្លាប់ទល់គ្នាគឺបង្វិលទល់មុខគ្នាវិញហើយ !

វាតានៅស្ងៀមមួយស្របក់ :

- ជាសំណាងល្អរបស់លោកហើយ ដែលគេមិនសម្លាប់លោកដោយប្រយោល !

- មែន បើគេមានបំណង ខ្ញុំគ្រឡប់ដៃមិនទាន់ទេ ចំណុចនេះយើងត្រូវតាមសង្កេតសិន ពុំទាន់អាចចោទទាំងស្រុងបានទេ !

- ខ្ញុំចូលចិត្តពិចារណា មុនការប្រព្រឹត្តដែរ ណ្ហើយចុះយើងបែកគ្នាត្រឹមនឹងចុះ ចាំជួបគ្នានៅតាមផ្លូវគ្រោះថ្នាក់ !

ចក្រីចាប់ដៃវាតាយ៉ាងស្អិត

- ឯងអាយុតិចជាងខ្ញុំ តែខ្ញុំចង់ចងមិត្តជាមួយឯង !

- អូ ! រីករាយណាស់ ដែលជនអាវ៉ាត់អារាយម្នាក់ដូចខ្ញុំបាន



ទទួលការរាប់អានពីលោក សមានចិត្តនេះហាក់កើតមានតាំងពីខ្ញុំបានជួបលោកលើកទី១ក្នុងនាមជាអ្នកទោសរបស់លោកម្ល៉េះ !

ចក្រីសើចស្រស់ :

- ខ្ញុំក៏ដូច្នេះដែរ១០ដងជួបគ្នា ខ្ញុំមានសំដីផ្អែម គ្មានពាក្យសំឡុតឯងទេ ! ចាំបានទេ ?

វាតាសើចខឹក១ :

- ភ្លេចមិនបានទេ លោកចង់លក់ខ្ញុំ ធ្វើមុខបែបកាច ខ្ញុំភ័យឡើងញ័រ !

ចក្រីទះស្មាមិត្តក្មេង :

- ខ្ញុំដឹងថាឯងគ្មានញញើត ខ្ញុំអីបន្តិចសោះ !

- ព្រោះខ្ញុំយល់ថា កំហុសខ្ញុំវាមិនដល់ថ្នាក់គៀបសួរចំលើយ ព្រោះខ្ញុំមិនមែនមកជាប់គុកក្នុងឋានៈជាអ្នកយកការណ៍ របស់នាគខ្មៅឯណា? ខ្ញុំមកព្រោះចិត្តចង់ទេតើ !

- លួមឈប់ហៅខ្ញុំថាលោកទៅវាតា.....!

- អរគុណ ចំពោះការរាប់អានរបស់លោក !

# វគ្គទី៣

# ផ្ការីកក្នុងដៃបង

យើងសំឡឹងមើលទៅប៊ីដាម្ដងវិញ បីយប់ជាប់ដែលស្រីមិនហ៊ានដេកឱ្យលក់ទេ តែរាត្រីទី៤នេះ នាងល្ងទប់លែងឈ្នះ ហើយស្រីគេងលក់លើកៅអីសាឡុងភ្នែកបិទជិត សក់រំសាយពេញស្មាគល់សុដន់ត្រចើលកំរើកតិចៗតាមខ្យល់ដង្ហើម សាច់ទ្រូងសខ្ចីផ្លុះនិងអាវដំណេក ! ពេលដឹងខ្លួនមាណពមិនព្រមញ៉ាំអីសោះ គេរស់ដោយសារតែទឹកក្រូចច្របាច់ពេលគេក្រោកនិងមានកម្លាំងដោយសារថ្នាំតែប៉ុណ្ណោះ។

កណ្ដាលអធ្រាត្រកម្លោះលោតចុះពីលើគ្រែ ហើយគេហាក់រំភើបណាស់ ពេលបើកភ្នែកប្រទះស្រីប៊ីដា :

- អាំ ! អូននៅក្បែរបងជានិច្ច អូនឈប់ទៅណាចោលបងហើយឬ?

កម្លោះអភ័ព្វបោះជំហានស្រាលៗសន្សឹមៗចម្រុះរបស់អ្នកផ្ដិតយ៉ាងថ្នមលើថ្ពាល់ស្រីស្រស់ ស្រង់យកក្លិនក្លែបក្រអូប នាងក្រមុំស្ទុះក្រោកស្រែកយ៉ៃរុញទ្រូង រដ្ឋកាលអស់ទំហឹងមាណពក្ដោបប្រាណបវរជាប់ឧទានទាំងរន្ធត់ !



- ម៉ាឡា ! បងមិនធ្លាប់ប្រមាថអូន ដោយប្រការណាទេ ម៉េចក៏អូនបែរជាខ្លាចបង ? ស្រឡាញ់គ្នាណាស់ តាំងពីអូននៅតូចដល់ពេញវ័យម៉េចក៏នៅមិនយល់ចិត្តគ្នា ?

នាងល្ទះកំភ្លៀងគេអស់ទំហឹង :

- ឆ្កួតតែឯងទៅ ! កុំមកប៉ះពាល់យើង ! លែង...!

ទំហឹងដៃដែលនាងភ័យ ធ្វើឱ្យមាត់រដ្ឋកាលបែកឈាមរឹមៗកម្លោះស្ទាបមាត់បែកឈាមអង្គុយទ្រឹង ហាក់កំពុងស្រម័យទៅឆ្ងាយគេមិនខឹងនឹងស្រីល្អទេ ភ្នែកគេវេជុំវិញខ្លួន ហាក់មិនអស់ចិត្តទៅវិញមាណវីឯណោះខ្លាចរត់ទៅឈរឆ្ងាយ ក្រែងមនុស្សឆ្កួតនេះកំរោលចូល!

នៅក្នុងបន្ទប់សាឡុងលោកកាលីកំពុងពិភាក្សា ជាមួយបុរសរូបស្អាតម្នាក់ ក្នុងវ័យ ២៩ ឆ្នាំ ចង្កាព្រែកបបូរមាត់ក្រហមស្ដើង ជាសញ្ញាចិត្តដាច់រាងស្រឡះដូចកូនកាត់ ភ្នែកវៃល្អណាស់ :

- រដ្ឋឈីឡា ប្អូនប្រុសរបស់ឯង ដូចជាបានស្រួលច្រើនហើយ ៥ថ្ងៃនេះប្លែកណាស់ តាំងពីបានប៊ីដាមកនៅក្បែរ ព្រោះនាងជារបស់សក្តិសិទ្ធដាស់អតីតកាលរបស់គេជំនួសម៉ាឡាដែលបាត់បង់ជីវិតទៅ !

អ្នកកម្លោះច្បងដែលមានឈ្មោះថា រដ្ឋឈីឡា ញញឹមដោយក្ដីពេញចិត្ត :

- គ្មានអ្វីដែលសប្បាយជាងនេះទេប៉ាប៉ា ! អូ ! ប៊ីដានោះជានរណា ?

- កូនស្រីអគ្គរដ្ឋទូត ប៊ីវ៉ាណា នោះអី !

- អូ ! ស្អាតដូចម៉ាឡាបេះបិទឬបា៉ ?

- នែ ! ល្មមលះបង់គំនិតអាក្រក់ចោលខ្លះហើយ ធ្វើបងគេត្រូវគិតដល់ប្អូនខ្លះ ឈាមដូចតែគ្នា ប៉ាលែងយោគយល់ហើយកុំធ្វើដូចកាលឯងដណ្តើមម៉ាឡាពីគេទៀត តិចថាប៉ាមិនបានប្រាប់មុន !

ឈីឡា ញាក់មុខ :

- ដូចប្រញាប់ស្រះរបងពេកហើយលោកប៉ា !

លោកកាលីជ្រួញចិញ្ចើម :

- ប្អូនស្រីរបស់ឯងក្រមុំស្ទូក ហើយជិតត្រឡប់មករស់នៅជុំគ្នាដែរ ឯងត្រូវមានអារម្មណ៍មួយថ្មី ថាប្អូនគេក៏ដូចប្អូនឯង !

- អ៊ាំ ! វដ្ឋនីមកវិញអង្កាល់ប៉ា? ខ្ញុំមិនដែលឃើញមុខនាងផងប្អូនខ្ញុំស្អាតឬទេ ?

លោកកាលីហួសចិត្តងើបចេញ ឆិរិទ្ធ វ៉ៃយរុទ្ធ ចូលមកអោនគោរព :

- អ្នកប្រុសសុំអញ្ជើញចូលពិសារបាយ !

- អរគុណ !

លោកកាលីនៅរង់ចាំកូនច្បងក្នុងបន្ទប់បាយ :

- ថ្ងៃនេះ ឯងទំនេរហើយមែនទេ ទើបបានមកបាយជុំគ្នាជាមួយប៉ា !



- ប៉ាជាអ្នកធ្វើការ ឯកូនពូកែខាងរកស៊ីទៅវិញ !

- ប្រហែលកាលកូនកើតមកមានខ្យល់បក់ខ្លាំងពេក បានជាស្លឹកឈើមួយសន្លឹកនេះជ្រុះឆ្ងាយពីគល់ !

លោកកាលីហួសចិត្តនិងនិយាយឈីឡាដែលមានសំដីខិល តែបញ្ជាក់ភាពឆ្លាតវៃ ចំណែកលោកវិញ ដូចជាធ្ងន់ចិត្តលើកូនច្បងនេះជាងគេទៅវិញ ព្រោះទោះជាគេធ្វើអ្វីទាស់ចិត្តក៏លោកបានត្រឹមតែស្តីបន្ទោសយ៉ាងថ្នមសំដីប៉ុណ្ណោះ !

បាយរួចឈីឡា ចង់ទៅមើលប្អូនទី២របស់គេ ! វ៉ៃយរុទ្ធចុចទ្វារកញ្ចក់ឱ្យឈីឡាចូល ។

ប៊ីដាងើបសំឡឹងឈីឡា ដោយទឹកមុខព្រួយបារម្ភជានិច្ច រូបនាងពេលនេះប្រៀបដូចសារិកាជាប់ទ្រុងឱ្យតែឃើញមុខបុរស គឺភ័យខ្លាចរហូតរដ្ឋកាលអង្គុយសំគុកសំឡឹងកែវទឹកក្រូច ដែលពុំទាន់ផឹកនៅលើគ្រែឈីឡាឈរភាំង ( អ៊្ហា! ស្អាតណាស់ហ្ន៎! ដូចម៉ាឡាបេះបិទ !) គេអង្អែលបបូរមាត់ ចោលពន្លឺភ្នែកយ៉ាងត្រជាក់លើគល់ទ្រូងដ៏ក្រពុំ ប៊ីដាស្រៀវខ្លួនស្ទុះងើបទៅអែបទូសំអាងរដ្ឋកាលក្រវាត់ កែវទឹកក្រូចចោលបោះជំហានមករកឈីឡាដោយទឹកមុខគួរឱ្យខ្លាច :

- ឯងចង់ធ្វើបាបម៉ាឡាទៀតហើយមែនទេ អាតិរិច្ឆាន ?

ឈីឡាបើកភ្នែកភ្លឺត្រចះ :

- អូហូ ! ឯងនិយាយបានត្រូវច្រើនណាស់ឥឡូវ តែចិត្តគំនិតមិនត្រូវគ្នា អញចង់ឱ្យឯងឆ្កួតរហូតវាប្រសើរជាង !

រដ្ឋកាលលើកដៃយឺតៗ ឈីឡាសើចកក្អឹក :

- ពេលជាមិនឈ្នះអញផង ទំរាំឆ្កួតទៀត ! តិចថាអញមិនយល់បងប្អូនវើយ !

វីយរុទ្ធរំលឹកទាំងញញើត :

- អ្នកប្រុស លោកម្ចាស់កំពុងខិតខំព្យាបាលអ្នកប្រុសទី២ អ្នកប្រុសកុំ....!

ឈីឡាជ្រួញចិញ្ចើម :

- ខ្ញុំមិនឃាត់ឃាំងការព្យាបាលរបស់គាត់ទេ តែពេលនេះខ្ញុំត្រូវការប៊ីដា កុំឱ្យប៉ាដឹងលីទេ? គាត់ចេញទៅក្រៅហើយ ឯងយកនាងទៅបន្ទប់ខ្ញុំមួយភ្លែតចាំយកមកឱ្យរដ្ឋកាលវិញចុះ! យូរៗទៅខ្លាចអាមនុស្សឆ្កួតបែបនេះវាដឹងខ្យល់អី !

ឈីឡា សើចស្រស់ដាក់ប៊ីដា :

- នៅកំដរបងវាសប្បាយជាងកំដរមនុស្សឆ្កួតណាអូន ! គេបង្វិលខ្លួនចេញវឹង ប៊ីដាភ័យណាស់ នាងយលបំណងរបស់ឈីឡា ស្រីរកទីសង្ស័យមគ្នានទេ មានតែរដ្ឋកាលគេឆ្កួតតែទន់ភ្លន់បំផុតជាមួយនាងស្រីស្មុះពួនក្រោយខ្នងអ្នកកម្លោះស្រមូម លែងខ្លាចគេដូចមុនហើយ :

- រដ្ឋកាលជួយខ្ញុំផង !



មាណពរំភើបចិត្តណាស់ អ្នកហាក់ទទួលនូវភាពផ្អែមល្ហែមរសាប់រសល់ពេញខ្លួន និងខួរក្បាលពេលនាងគំហកកំហែងតោះតើយអារម្មណ៍អ្នកវិលខ្វាល់រកដើមចុងមិនឃើញទេ ស្រាប់តែពេលនេះកម្លោះនឹកចាំយ៉ាងច្បាស់នៅព្រឹត្តិការណ៍មួយ ដែលអ្នកបានជួយស្រីល្អជាដំបូងគឺអ្នកធ្លាប់ជួយនាងពីប្រុសខិលខូចមួយចំនួន ហើយនាងរត់មកអ្នកឱ្យជួយ ដូចពេលនេះអញ្ចឹងរដ្ឋកាលឈរជ្រែងសំឡក់វីយរុទ្ធ !

- បើឯងហ៊ានចូលមួយជំហានទៀត កុំថាអញកាចវើយ ! ឬកពាកំពុងប្រែប្រួលបង្ហាញលក្ខណៈអង់អាចមិនសឹៗដូចមុនទៅវីយរុទ្ធអរណាស់ តែម្យ៉ាងខ្លាចអ្នកប្រុសទី១ កំពុងតែអេះអុញសំឡេងមួយបន្លឺយ៉ាងស្ងប់ :

- ថយចេញវីយរុទ្ធ ! អញមិនទុកចិត្តឈីឡាទេ បានជាអញមកវិញឥឡូវមែន ទុកពេលឱ្យរដ្ឋកាលសំរាកខួរក្បាលឮហើយនៅ ? វីយរុទ្ធរួញខ្លួនចេញមកវិញយ៉ាងលឿន គេបិទបន្ទប់ដូចដើមលោកកាលីញញឹមពីក្រៅបន្ទប់ :

- រដ្ឋកាលប៉ាបំពេញបំណងកូនទាំងអស់ ឱ្យតែកូនស្ងប់អារម្មណ៍សំរាកឱ្យបានច្រើនលីទេ ? កម្លោះជ្រួញចិញ្ចើមសំឡឹងមុខឪពុកយ៉ាងយូររួចរអ៊ូតិចៗ :

- ខ្ញុំធ្លាប់ជួបអ្នកឯងនៅកន្លែងណា ? ជួបនៅទីណា ? អូ !....

- កូនធ្លាប់ជួបប៉ានៅទីនេះរាល់ថ្ងៃ នេះផ្ទះរបស់យើងណារដ្ឋ-កាល !

មាណពបង្វិលខ្លួនមករកនាងក្រមុំ :

- ទេ ! យើងមិនស្តាប់សំដីឯងទេ ម៉ាឡា បងជឿតែអូនម្នាក់ បងធ្លាប់ប្រាប់អូនថា ដល់ការរួចនាំអូនទៅលេងផ្ទះធំរបស់បងតើទីនេះមែនទេអូន !

នាងក្រមុំអេះអុញឆ្លើយយ៉ាងស្រាល :

- ចំា ! ផ្ទះនេះហើយ !

រដ្ឋកាលសើចយ៉ាងសប្បាយ :

- អូ ! ម៉ាឡាមិនស្អប់បងទៀតទេឥឡូវ ? ផ្ទះបងស្អាតទេ ? អូនថាទៅមើល ?

- ចំា ! ស្អាត !

មាណពចាប់ដៃស្រីល្អលោសថ្នមៗនាងអៀនដកដៃចេញលោក កាលី បន្លឺដាច់ណាត់ :

- ប៊ីដា នាងត្រូវចេះសំរបហើយទន់ភ្លន់ជាមួយគេ ដើម្បីឱ្យខួរក្បាលគេស្ងប់ខ្លះផង កុំភ្លេចថា គេជាពេលណានាងបាន ទៅជួបម្តាយឪពុកពេលនោះ សេរីភាពរបស់នាងគឺរដ្ឋកាល អ្នកសំរេចណាដឹងទេ ?

ប៊ីដាខាំមាត់មិនចេញស្តី បុរសនេះជាអ្នកណា ក៏មានអំណាចម្ល៉េះ ?



ផ្ទះសុទ្ធតែគន្លឹះយន្ត អ្នកបំរើអោនលំទោនគ្រប់គ្នា ជួនកាលគេស្ទៀកពាក់ជាភ្នាក់ងារទៀតផង ! លោកកាលីបោះជំហានយ៉ាងលឿនចូលទៅរកឈីឡាក្នុងបន្ទប់មាណពភ្ញាក់ :

- អូ ! ប៉ាមកវិញហើយ ?

- ឈីឡា ! ប៉ាមិនធ្លាប់ស្តីបន្ទោសកូនទេ តែពេលនេះ ប៉ាចង់ឱ្យកូនឈប់រវល់និងប៊ីដាទៅ កុំឱ្យរដ្ឋកាលវាកំរើកចិត្តពេកក្រែងព្យា-បាលមិនជា ឯងស្តាប់សំដីប៉ាម្តងទៅមើល ?

ឈីឡាអេះអុញ :

- ខ្ញុំឈប់ហើយប៉ា !

- ល្អណាស់សំរាកចុះ កូនហត់នឿយច្រើន ប៉ាមិនមែនមិនដឹងទេ ក្នុងការកាន់កាប់មរតករបស់យើង តែគួរបង្អង់រឿងស្រីខ្លះទៅ !

ឈីឡាសើចញឹមៗឈរកោពុកមាត់មិនចេញស្តី។

រដ្ឋកាលញញឹម សំឡឹងប៊ីដា :

- អូនគេងទៅ កុំខ្លាចពួកគេអី ! បងហ៊ានប្តូរដល់ជីវិត ដើម្បីស្នេហ៍យើង ! អូ ! ម្តាយបងទៅណាហើយ ? គេយកអូនទៅលាក់ឯណាបានជាបងរកមិនឃើញ ?

ប៊ីដា ចាប់ភ្លឹកបានច្រើន គេនិយាយត្រឡប់ត្រឡិន តែមិនសូវខុសទេ មើលទៅគេដូចជាចាំរឿងគេនឹងសង្សារបានច្រើន ក្រៅពីនោះអត់រំលឹកសោះ ស្រីចាប់ផ្តើមអាណិតរដ្ឋកាល គេទើបនឹងឆ្កួត ពុំមែន